## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខៈ ២៥៦ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# នីតិវិធីនៃការបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានលាឈប់
- បានឃើញសេចក្តីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៨៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- បានឃើញសេចក្តីសម្រេចលេខ ៥៨៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលគំនិតស្តីពីការគ្រប់គ្រងលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

- បានឃើញសេចក្ដីសម្រេចលេខ ៥៨៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលដៅ

សេចក្ដីសម្រេចនេះ មានគោលដៅធានាប្រសិទ្ធភាពនៃការបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ដូចតទៅ៖

- ដើម្បីបង្កើនជំនឿទុកចិត្តពីភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ដើម្បីផ្ដល់លទ្ធផលបោះឆ្នោតបឋមបានឆាប់រហ័ស យ៉ាងត្រឹមត្រូវ ទូលំទូលាយ និងតម្លាភាពដល់ភាគីពាក់ព័ន្ធទាំងអស់
- ដើម្បីធ្វើជាព័ត៌មាន និងទិន្នន័យសំខាន់ក្នុងការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន និងលទ្ធផលបោះឆ្នោតផ្លូវការ។

### ប្រការ ២.- គោលបំណង

សេចក្ដីសម្រេចនេះ មានគោលបំណងបញ្ញត្តនីតិវិធីនៃការបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨។

### ប្រការ ៣.- វិសាលភាព

សេចក្ដីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨។

# ជំពូកទី ២
# សមត្ថកិច្ច

## ប្រការ ៤.- គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម

គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ហៅកាត់ថា "គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម" បង្កើតឡើងតាមសេចក្តីសម្រេចលេខ ៥៨៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ មានសមត្ថកិច្ចលើការគ្រប់គ្រងលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨។

គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម មានអនុគណៈកម្មការចំនួន ៣ ជាជំនួយការ។

- អនុគណៈកម្មការសម្របសម្រួល
- អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
- អនុគណៈកម្មការផ្សព្វផ្សាយ។

សមាសភាពអនុគណៈកម្មការខាងលើនេះ ត្រូវចាត់តាំងដោយលិខិតបង្គាប់ការរបស់អគ្គលេខាធិការ គ.ជ.ប។

## ប្រការ ៥.- ភារកិច្ចរបស់អនុគណៈកម្មការសម្របសម្រួល

អនុគណៈកម្មការសម្របសម្រួល មានភារកិច្ច ដូចតទៅ៖

- ចាត់ចែងអនុវត្តនីតិវិធីបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- រៀបចំ និងគ្រប់គ្រងការងាររដ្ឋបាលរបស់គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម
- ទំនាក់ទំនង និងសម្របសម្រួលការងារទទួល និងបញ្ជូនឯកសាររវាងអនុគណៈកម្មការនានា ដើម្បីបញ្ជូនទៅ គ.ជ.ប និងទទួលមកវិញ
- ទំនាក់ទំនងជាមួយក្រុមសម្របសម្រួលនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) ពាក់ព័ន្ធនឹងរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) បញ្ជូនមក
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការ ឬ/និងអគ្គលេខាធិការ គ.ជ.ប ប្រគល់ឱ្យ។

## ប្រការ ៦._ ភារកិច្ចរបស់អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ មានភារកិច្ច ដូចតទៅ៖

- ចាត់ចែងអនុវត្តនីតិវិធីបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- បោះពុម្ពរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យដែល គឃ.សប បញ្ជូនមកតាមរាជធានី ខេត្ត នីមួយៗ រួចធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
- ធ្វើការកែតម្រូវទិន្នន័យនៅលើទិន្នន័យដែលបានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីដែល គឃ.សប បញ្ជូនមក ក្នុងករណីទិន្នន័យក្នុងរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែលបានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីដែល គឃ.សប ផ្ញើមក មានភាពខុសគ្នា
- បញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យ ទៅអនុគណៈកម្មការសម្របសម្រួល ដើម្បីសុំការយល់ព្រមពី គ.ជ.ប តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម និងអគ្គលេខាធិការ គ.ជ.ប
- បញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍ទិន្នន័យដែលបានកែតម្រូវទិន្នន័យដែលបានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីដែល គឃ.សប ផ្ញើមក ទៅអនុគណៈកម្មការសម្របសម្រួល ដើម្បីសុំការសម្រេចពី គ.ជ.ប តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម និងអគ្គលេខាធិការ គ.ជ.ប
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការ ឬ/និងអគ្គលេខាធិការ គ.ជ.ប ប្រគល់ឱ្យ។

## ប្រការ ៧._ ភារកិច្ចរបស់អនុគណៈកម្មការផ្សព្វផ្សាយ

អនុគណៈកម្មការផ្សព្វផ្សាយ មានភារកិច្ច ដូចតទៅ៖

- ចាត់ចែងអនុវត្តនីតិវិធីបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- ផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមតាមរយៈទូរទស្សន៍ និងវិទ្យុជាតិ និង Facebook Page និងគេហទំព័ររបស់ គ.ជ.ប បន្ទាប់ពីបានការយល់ព្រមពី គ.ជ.ប

- បញ្ជូនតារាងលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្តនីមួយៗដែល គ.ជ.ប បានយល់ព្រមរួចហើយ ទៅ គធ.ខប ពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយនៅតាមរាជធានី ខេត្ត
- ទំនាក់ទំនង និងសហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា និង អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ដើម្បីផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម តាមរយៈទូរទស្សន៍ និងវិទ្យុ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការ ឬ/និងអគ្គលេខាធិការ គ.ជ.ប ប្រគល់ឱ្យ។

## ប្រការ ៨.- ក្រុមសម្របសម្រួលនៅ គធ.ខប

### ៨.១ សមាសភាព

គធ.ខប ត្រូវបង្កើតក្រុមសម្របសម្រួល ដើម្បីធ្វើការសម្របសម្រួលជាមួយ គឃ.សប និងគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម តាមលិខិតបង្គាប់ការរបស់ គធ.ខប។ ក្រុមសម្របសម្រួលនៅ គធ.ខប មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ប្រធាន លគធ.ខប | ជាប្រធាន |
| ២- | សមាជិក គធ.ខប ទទួលបន្ទុកផ្នែកប្រតិបត្តិការបោះឆ្នោត និងបញ្ជីបោះឆ្នោត | ជាអនុប្រធាន |
| ៣- | សមាជិក គធ.ខប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និង វិវាទកម្ម និងសន្តិសុខបោះឆ្នោត | ជាសមាជិក |
| ៤- | ជំនួយការបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងព័ត៌មានសាធារណៈ (គ្រូបង្ហាត់) | ជាសមាជិក |
| ៥- | មន្ត្រីប្រតិបត្តិការ និងភស្តុភារ | ជាសមាជិក |
| ៦- | លេខាធិការ | ជាសមាជិក |

### ៨.២ ភារកិច្ច

ក្រុមសម្របសម្រួលនៅ គធ.ខប មានភារកិច្ច ដូចតទៅ៖

- ចាត់ចែង និងសម្របសម្រួលការអនុវត្តនីតិវិធីបញ្ចូល បញ្ជូន ត្រួតពិនិត្យ និង ផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- ទំនាក់ទំនង និងសហការជាមួយអនុគណៈកម្មការសម្របសម្រួលពាក់ព័ន្ធនឹង រូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)

- ទំនាក់ទំនងជាមួយ គឃ.សប ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីបញ្ចូល បញ្ជូនលទ្ធផលបោះឆ្នោតបឋម
- ប្រមូលក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែល គឃ.សប បញ្ជូនមក និងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ និងរក្សាទុកជាឯកសារត្រៀមសហការជាមួយអនុគណៈកម្មការសម្របសម្រួល ក្នុងករណីចាំបាច់
- ចាត់ចែង និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមនៅតាមរាជធានី ខេត្តរៀងៗខ្លួន ដែលអនុគណៈកម្មការផ្សព្វផ្សាយ បានផ្ញើជូន
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គធ.ខប និង គ.ជ.ប ប្រគល់ឱ្យ។

## ប្រការ ៩.- គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) មានភារកិច្ច ដូចតទៅ៖

- ចាត់ចែងអនុវត្តនីតិវិធីបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- ទទួលកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត (គ.ក.រ)
- ស្កេន (Scan) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានទទួល (ដោយមិនរង់ចាំឱ្យគ្រប់ការិយាល័យ) បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ រួចវាយបញ្ចូលទិន្នន័យពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ទៅក្នុងប្រព័ន្ធកម្មវិធីគ្រប់គ្រងលទ្ធផលបោះឆ្នោតបឋម
- គណនាបូកសរុបទិន្នន័យពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានទទួល (ដោយមិនរង់ចាំឱ្យគ្រប់ការិយាល័យ) រួចបំពេញក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥)
- ធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់រវាងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យបោះឆ្នោត និងរវាងលទ្ធផលទិន្នន័យសរុបក្នុងឃុំ សង្កាត់ដែលគណនាដោយកម្មវិធី ជាមួយនឹងក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) ដែលគណនាដោយ គឃ.សប ឱ្យបានត្រឹមត្រូវ មុននឹងបញ្ជូនតាមអ៊ីនធឺណិត ទៅ គ.ជ.ប

- បញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែលបានវាយបញ្ចូលទៅ គ.ជ.ប តាមអ៊ីនធឺណិត
- បញ្ជូនក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) ដែលគណនាដោយ គឃ.សប ១ (មួយ) ច្បាប់ ដោយភ្ជាប់ជាមួយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពាក់ព័ន្ធដោយផ្ទាល់ ឬតាមរយៈគ្រូបង្ហាត់ប្រចាំក្រុង ស្រុក ខណ្ឌ ទៅ គធ.ខប
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គធ.ខប និង គ.ជ.ប ប្រគល់ឱ្យ។

## ជំពូកទី ៣
## នីតិវិធី

**ប្រការ ១០.-**

គឃ.សប នៅថ្ងៃបោះឆ្នោត បន្ទាប់ពីបញ្ចប់ការរាប់សន្លឹកឆ្នោត ត្រូវប្រមូលជាបន្ទាន់នូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពី គ.ក.រ នានាក្នុងឃុំ សង្កាត់។

ក្រោយពីទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) គឃ.សប ត្រូវអនុវត្តកិច្ចការ ដូចខាងក្រោម៖

- ប្រធាន គឃ.សប ត្រូវចារបញ្ជាក់ពីការបានទទួលនៅលើផ្នែកខាងលើនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួល រួចចុះហត្ថលេខា និងបោះត្រា គឃ.សប
- សមាជិក គឃ.សប ដែលចេះប្រើប្រាស់កុំព្យូទ័រ ត្រូវស្កេនកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានទទួលពី គ.ក.រ បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ហើយវាយបញ្ចូលទិន្នន័យពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២) ទៅក្នុងប្រព័ន្ធកម្មវិធីគ្រប់គ្រងលទ្ធផលបោះឆ្នោតបឋម ដែលកម្មវិធីនឹងបូកសរុបលទ្ធផលទិន្នន័យសរុបក្នុងឃុំ សង្កាត់ដោយស្វ័យប្រវត្តិ
- គណនាបូកសរុបទិន្នន័យពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានទទួល (ដោយមិនរង់ចាំឱ្យគ្រប់ការិយាល័យ) រួចបំពេញក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥)
- ធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់រវាងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យបោះឆ្នោត និងរវាងលទ្ធផលទិន្នន័យសរុបក្នុងឃុំ សង្កាត់ដែលគណនាដោយកម្មវិធី ជាមួយនឹងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) ដែលគណនាដោយ គឃ.សប ឱ្យបានត្រឹមត្រូវ មុននឹងបញ្ជូនតាមអ៊ីនធឺណិតទៅ គ.ជ.ប

- ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ ប្រធាន គឃ.សប ត្រូវផ្តិតម្រាមដៃ ដើម្បីអនុញ្ញាតឱ្យធ្វើការបញ្ជូន (Authorize) នៅលើម៉ាស៊ីនស្កេនម្រាមដៃរួចសមាជិក គឃ.សប ដែលចេះប្រើប្រាស់កុំព្យូទ័រត្រូវបញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែលបានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីមកកាន់ម៉ាស៊ីនមេ (Server) នៅ គ.ជ.ប តាមរយៈ Virtual Private Network (VPN)។ គធ.ខប ត្រូវទាញយកទិន្នន័យទាំងនេះ ដើម្បីធ្វើការតាមដាន និងផ្ទៀងផ្ទាត់។
- ក្រោយពីបានបញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យទៅ គ.ជ.ប រួចហើយ ប្រសិនបើនៅទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតផ្សេង ដែលមិនបានបញ្ជូនមកពេលមុន គឃ.សប ត្រូវចាត់ចែងកិច្ចការដូចក្នុងគំនូសទី១ គំនូសទី២ គំនូសទី៣ គំនូសទី៤ និងគំនូសទី៥ ខាងលើ
- បញ្ជូនក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) ដែលគណនាដោយ គឃ.សប ១ (មួយ) ច្បាប់ ដោយភ្ជាប់ជាមួយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពាក់ព័ន្ធដោយផ្ទាល់ ឬតាមរយៈគ្រូបង្គាត់ប្រចាំក្រុង ស្រុក ខណ្ឌ ទៅ គធ.ខប។

**ប្រការ ១១.-**

នៅពេលរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែល គឃ.សប បានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីបានបញ្ជូនមកដល់ម៉ាស៊ីនមេនៅ គ.ជ.ប អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ត្រូវអនុវត្តនូវកិច្ចការ ដូចខាងក្រោម៖

- បោះពុម្ពរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) របាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យ និងលទ្ធផលទិន្នន័យសរុបក្នុងឃុំ សង្កាត់ដែល គឃ.សប បញ្ជូនមក ដោយរៀបចំដាក់តាមរាជធានី ខេត្តនីមួយៗ រួចធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ម្តងមួយការិយាល័យបោះឆ្នោតនូវលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់ លេខកូដការិយាល័យបោះឆ្នោត លំដាប់លេខរៀង ឈ្មោះគណបក្សនយោបាយ និងតួលេខសំឡេងឆ្នោតរបស់គណបក្សនយោបាយទទួលបានរវាងរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ជាមួយនឹងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យដែល គឃ.សប បញ្ជូនមក

- បន្ទាប់ពីបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឃើញថា៖
  + ត្រឹមត្រូវហើយ អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ត្រូវបញ្ជូនទៅអនុគណៈកម្មការសម្របសម្រួល ដើម្បីសុំការយល់ព្រមពី គ.ជ.ប តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម និងអគ្គលេខាធិការ គ.ជ.ប។
  + ទិន្នន័យក្នុងរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងរបាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យដែល គឃ.សប បញ្ជូនមក មានភាពខុសគ្នា អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ត្រូវធ្វើការកែតម្រូវទិន្នន័យនៅលើទិន្នន័យដែលបានវាយបញ្ចូលក្នុងប្រព័ន្ធកម្មវិធីដែល គឃ.សប បញ្ជូនមក រួចបញ្ជូនទៅអនុគណៈកម្មការសម្របសម្រួល ដើម្បីសុំការសម្រេចពី គ.ជ.ប តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម និងអគ្គលេខាធិការ គ.ជ.ប។

## ប្រការ ១២.-

អនុគណៈកម្មការសម្របសម្រួល នៅពេលទទួលបានរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) របាយការណ៍បញ្ចូលទិន្នន័យតាមការិយាល័យ និងលទ្ធផលទិន្នន័យសរុបក្នុងឃុំ សង្កាត់ដែលអនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បានបោះពុម្ព និងត្រួតពិនិត្យផ្ទៀងផ្ទាត់រួច ត្រូវ៖

- រៀបចំបញ្ជូនឯកសារទាំងអស់ដែលអនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជូនមកតាមរាជធានី ខេត្តនីមួយៗ ទៅ គ.ជ.ប ពិនិត្យ សម្រេចតាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម និងអគ្គលេខាធិការ គ.ជ.ប
- បន្ទាប់ពីបានទទួលការយល់ព្រមពី គ.ជ.ប អនុគណៈកម្មការសម្របសម្រួលត្រូវបញ្ជូនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) Chart និងតារាងសំឡេងឆ្នោតដែលគណបក្សនយោបាយទទួលបានតាមរាជធានី ខេត្តនីមួយៗ ទៅអនុគណៈកម្មការផ្សព្វផ្សាយ ដើម្បីធ្វើការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុជាតិ និងបញ្ជូនទៅធ្វើការផ្សព្វផ្សាយ តាមរយៈគេហទំព័រ គ.ជ.ប និងបណ្ដាញសង្គមរបស់ គ.ជ.ប។

## ប្រការ ១៣.-

អនុគណៈកម្មការផ្សព្វផ្សាយត្រូវធ្វើការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម តាមបណ្ដាញអ៊ីនធឺណិត និងតាមទូរទស្សន៍ ព្រមទាំងវិទ្យុជាតិ។

ការផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុជាតិ លុះត្រាតែបានទទួលទិន្នន័យយ៉ាងតិច ៥០% (ហាសិប) ភាគរយនៃចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ។

ការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុជាតិត្រូវធ្វើឡើងចាប់ពីម៉ោង ១៨:០០ រហូតដល់ម៉ោង ១:០០ នៃយប់ថ្ងៃបោះឆ្នោត ដោយធ្វើការផ្សព្វផ្សាយវិលជុំ ៣ ដង នៃរាជធានី ខេត្តនីមួយៗ។ បើសិនមិនអស់នឹងបន្តទៅព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោតមួយព្រឹកទៀត។ ការថតផ្សាយតាមរយៈទូរទស្សន៍ជាតិ ត្រូវធ្វើឡើងនៅទីស្តីការ គ.ជ.ប។

ការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម ត្រូវធ្វើឡើងតាមគេហទំព័រដែលមានឈ្មោះថា rms.necelect.org.kh និងតាម Facebook Page របស់ គ.ជ.ប ផងដែរ។

ការផ្សព្វផ្សាយតាមបណ្តាញអ៊ីនធឺណិតត្រូវធ្វើឡើងទៅតាមចំនួនរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែលបានទទួលពី គយ.សប។ ទម្រង់នៃការផ្សព្វផ្សាយ គឺទម្រង់ជា Chart តាមរាជធានី ខេត្ត និងទម្រង់ជាតារាងសំឡេងឆ្នោតដែលគណបក្សនយោបាយទទួលបានតាមការិយាល័យបោះឆ្នោត ដោយមានភ្ជាប់ជាមួយរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

**ប្រការ ១៤.-**

ក្រុមសម្របសម្រួលនៅ គធ.ខប ត្រូវប្រមូលក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែល គយ.សប បញ្ជូនមក និងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ និងរក្សាទុកជាឯកសារត្រៀមសហការជាមួយអនុគណៈកម្មការសម្របសម្រួល ក្នុងករណីចាំបាច់។

គធ.ខប ត្រូវផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមក្នុងរាជធានី ខេត្ត ដែលអនុគណៈកម្មការផ្សព្វផ្សាយផ្ញើជូន តាម Facebook Page របស់ លគធ.ខប និងវិទ្យុក្នុងរាជធានី ខេត្ត ហើយអាចធ្វើការផ្សព្វផ្សាយដំណាលគ្នានឹងការផ្សព្វផ្សាយរបស់ គ.ជ.ប។

**ប្រការ ១៥.-**

រាល់រូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យលទ្ធផលបោះឆ្នោតបឋមទាំងអស់ នឹងយកមកធ្វើជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតបណ្តោះអាសន្ន និងលទ្ធផលបោះឆ្នោតផ្លូវការ។

ក្នុងករណីមានការកែសម្រួលលទ្ធផលនៃការបោះឆ្នោត តាមរយៈការកែតម្រូវកំហុសតួលេខ ឬ/និងយន្តការនៃការដោះស្រាយពាក្យបណ្តឹងតាមថ្នាក់នីមួយៗ គ.ជ.ប ត្រូវធ្វើការបង្ហោះរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទិន្នន័យដែលកែតម្រូវទាំងនោះនៅលើគេហទំព័ររបស់ គ.ជ.ប ដើម្បីឱ្យភាគីពាក់ព័ន្ធមានមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ និងប្រៀបធៀប។

**ប្រការ ១៦.-**

រាល់ទិន្នន័យនៃលទ្ធផលបោះឆ្នោតបឋមតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានអនុញ្ញាតឱ្យនាយកដ្ឋានប្រតិបត្តិការ និង គធ.ខប យកពី Database ពីម៉ាស៊ីនមេនៅ គ.ជ.ប ទៅប្រើប្រាស់។

**ប្រការ ១៧.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប គណៈកម្មការគ្រប់គ្រងគម្រោងលទ្ធផលបោះឆ្នោតបឋម គធ.ខប លគធ.ខប និង គឃ.សប ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**សុិក ប៊ុនហុក**

**<u>ចម្លងជូនៈ</u>**

- សមាជិក គ.ជ.ប
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# លំហូរនៃការបញ្ចូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបឋម
# សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៦ ឆ្នាំ២០១៨

